ការកំណត់ពេល 48 ខែរបស់កម្មវិធី CALWORKS

ការកំណត់ពេល 48 ខែរបស់កម្មវិធី CalWORKs ស្តីពីជំនួយ

ចាប់ផ្តើមនៅថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2011 ជំនួយមនុស្សធំម្នាក់ (ឪពុក ឬម្តាយ ឪពុក ឬម្តាយចុង និង/ឬអ្នកមើលថែជាសាច់ញាតិ) អាចទទួលបានជំនួយសាច់ប្រាក់ត្រឹមតែរយៈពេល 48 ខែ (4 ឆ្នាំ) ពីកម្មវិធីឱកាសការងារ និងទំនួលខុសត្រូវចំពោះក្មេង រដ្ឋ California (CalWORKs)។ នេះរួមទាំង ជំនួយសាច់ប្រាក់ដែលអ្នកទទួលបានពីកម្មវិធីជំនួយបណ្តោះអាសន្នរបស់សហព័ន្ធសម្រាប់គ្រួសារក្រីក្រ (TANF) របស់រដ្ឋ California និងរបស់រដ្ឋផ្សេងទៀត។

ការកំណត់ពេល 48 ខែមិនអនុវត្តចំពោះ៖

- កុមារ
- ការថែទាំកុមារ
- អត្ថប្រយោជន៍ពីកម្មវិធី Medi-Cal
- អត្ថប្រយោជន៍ពីកម្មវិធី CalFresh
- ជំនួយដែលអ្នកទទួលបានពីរដ្ឋ California ឬរដ្ឋផ្សេងទៀត នៅក្រោមកម្មវិធីជំនួយគ្រួសារមានកូនក្នុងបន្ទុក (AFDC) នៅមុនថ្ងៃទី 1 ខែមករា ឆ្នាំ 1998។

ការពិតដែលអ្នកត្រូវដឹងអំពីការកំណត់ពេល 48 ខែរបស់ CalWORKs

ការលើកលែងការកំណត់ពេល - "ការបញ្ឈប់ម៉ោង"

មួយខែនៃការទទួលជំនួយសាច់ប្រាក់ **មិន** រាប់ចូលទៅក្នុងការកំណត់ពេល 48 ខែរបស់កម្មវិធី CalWORKs ទេ បើពេលវេលាណាមួយនៅអំឡុងខែនោះ **អ្នក**៖

- ពិការ *(អ្នកត្រូវមានកស្តុតាងខាងវេជ្ជសាស្ត្រស្តីពីពិការភាព ដែលមានរយៈពេលយ៉ាងតិចណាស់ 30 ថ្ងៃ។)*
- អាយុ 60 ឆ្នាំ ឬច្រើនជាងនេះ។
- មើលថែអ្នកជំងឺ ឬជនអសមត្ថភាព ដែលរស់នៅក្នុងផ្ទះរបស់អ្នក ដែលរារាំងអ្នកពីការធ្វើការ ឬចូលរួមនៅក្នុង សកម្មភាពកម្មវិធីពីវ៉ែលហ្វែរទៅធ្វើការ។
- មើលថែកុមារនៅក្នុងបន្ទុករបស់តុលាការ ឬកុមារដែលមានហានិភ័យក្នុងការដាក់នៅក្រោមការមើលថែចិញ្ចឹម ដែលរារាំងអ្នកពីធ្វើការ ឬចូលរួមនៅក្នុងសកម្មភាពកម្មវិធីពីវ៉ែលហ្វែរទៅធ្វើការ។
- ជាជនរងគ្រោះនៃការរំលោភបំពាននៅក្នុងគ្រួសារ ហើយខោនធីបោះបង់ការកំណត់ពេល 48 ខែ។
- រស់នៅក្នុងទឹកដីជនជាតិឥណ្ឌា ដូចឱ្យនិយមន័យដោយច្បាប់សហព័ន្ធ ឬភូមិកំណើត Alaskan ដែលមានមនុស្សពេញវ័យយ៉ាងហោចណាស់ 50 ភាគរយគ្មានការងារធ្វើ។
- ផ្តល់ការលើកលែងពីការចូលរួម និងការកំណត់ពេលនៃជំនួយសាច់ប្រាក់ ត្រូវផ្អែកលើការថែទាំកុមារ ដែលមានអាយុពី 0 ទៅ 23 ខែ។ *(ការលើកលែងនេះមានតែម្តងទេ។)*

"ការបញ្ឈប់ម៉ោង" បន្ថែមទៀតចំពោះការកំណត់ពេល 48 ខែរបស់កម្មវិធី CalWORKs

រយៈពេលមួយខែ **មិន** រាប់ទេ បើ៖

- អ្នកមិនទទួលបានជំនួយសាច់ប្រាក់របស់ CalWORKs សម្រាប់ខ្លួនអ្នក ដោយសារជំនួយរបស់អ្នកមានតិចជា 10 ដុល្លារ អ្នកត្រូវបានដាក់ទណ្ឌកម្ម ឬអ្នកមិនមានសិទ្ធិទទួលបានដោយហេតុផលផ្សេងទៀត។
- ជំនួយសាច់ប្រាក់របស់អ្នកត្រូវបានបង់បង់សងទាំងស្រុង ដោយការទាមទារពីកម្មវិធីឧបត្ថម្ភកុមារ។
- អ្នកមិនទទួលបានជំនួយសាច់ប្រាក់ មានការងារធ្វើ ឬទទួលបានសេវាគាំពារ ដូចជា ការថែទាំកុមារ ការដឹកជញ្ជូន ឬការគ្រប់គ្រង សំណុំរឿង។

សម្រាប់ព័ត៌មានបន្ថែមដោយមិនគិតពីការកំណត់ពេល សូមមើលទំព័រខាងក្រោយ។

ការកំណត់ពេល 48 ខែរបស់កម្មវិធី CALWORKS

ការលើកលែងការកំណត់ពេល - "ការពន្យាពេល"

អ្នកអាចទទួលបានជំនួយសាច់ប្រាក់ច្រើននៅក្រោយផុតរយៈពេល 48 ខែ បើ **គ្រប់** ឪពុកម្តាយ ឪពុកម្តាយចុង និង/អ្នកមើលថែជាសាច់ញាតិដែលផ្តល់ជំនួយនៅក្នុងផ្ទះ បានស្ថិតនៅក្នុងស្ថានភាពណាមួយដូចខាងក្រោម៖

- មើលថែអ្នកជំងឺ ឬជនអសមត្ថភាព ដែលរស់នៅក្នុងផ្ទះរបស់អ្នក ដែលរារាំងអ្នកពីការធ្វើការ ឬចូលរួមនៅក្នុងសកម្មភាពកម្មវិធីពីវ៉ែលហ្វែរទៅធ្វើការ។
- អាយុ 60 ឬច្រើនជាងនេះ
- មើលថែកុមារនៅក្នុងបន្ទុករបស់តុលាការ ឬកុមារដែលមានហានិភ័យក្នុងការដាក់នៅក្រោមការមើលថែចិញ្ចឹម ដែលរារាំងអ្នកពី ធ្វើការ ឬចូលរួមនៅក្នុងសកម្មភាពកម្មវិធីពីវ៉ែលហ្វែរទៅធ្វើការ។
- ត្រូវបានវាយតម្លៃដោយខោនធី និងត្រូវបានរកឃើញថា មិនអាចបន្តការងារ ឬចូលរួមនៅក្នុងសកម្មភាពកម្មវិធីពីវ៉ែលហ្វែរទៅធ្វើការ។ ការលែកលែងនេះអនុវត្តនៅពេលមនុស្សពេញវ័យមានប្រវត្តិចូលរួមនៅក្នុងវិធានស្តីពីកម្មវិធីពីវ៉ែលហ្វែរទៅធ្វើការតែប៉ុណ្ណោះ។
- មិននៅក្នុងអង្គភាពជំនួយ (AU) ដោយហេតុផលណាមួយក្រៅពីការដល់ការកំណត់ពេល 48 ខែ។
- ពិការ និងទទួលបានប្រភេទនៃអត្ថប្រយោជន៍សម្រាប់ពិការភាព ហើយពិការភាពបានរារាំងអ្នកពីការធ្វើការ ឬចូលរួមនៅក្នុងសកម្មភាពកម្មវិធីពីវ៉ែលហ្វែរទៅធ្វើការ។ អត្ថប្រយោជន៍ដែលមានលក្ខណសម្បត្តិសម្រាប់រឿងនេះ គឺ៖ ការធានារ៉ាប់រង State Disability Insurance ការធានារ៉ាប់រង Worker's Compensation Temporary Disability Insurance សេវា In-Home Supportive Services អត្ថប្រយោជន៍របស់កម្មវិធី State Supplementary Program។
- បើមនុស្សពេញវ័យតែម្នាក់នៅក្នុងផ្ទះជួបតាមតម្រូវការពន្យា នោះអ្នកមិនមានលក្ខណសម្បត្តិទទួលបានការពន្យាជំនួយសាច់ប្រាក់ទេ។ មនុស្សពេញវ័យទាំងពីរនេះត្រូវតែជួបតាមតម្រូវការពន្យាមួយក្នុងការពន្យាទាំងនេះ ប៉ុន្តែមនុស្សពេញវ័យម្នាក់អាចឆ្លើយតបទៅនឹងការពន្យាផ្សេងទៀតបាន។

ការបោះបង់ការកំណត់ពេល 48 ខែរបស់ CalWORKs សម្រាប់ការពន្យាជំនួយ

បើអ្នកជាជនរងគ្រោះនៃការរំលោភបំពាននៅក្នុងគ្រួសារ ហើយខោនធីបានកំណត់ថា លក្ខខណ្ឌ ឬស្ថានភាពរបស់អ្នករារាំងលទ្ធភាពរបស់អ្នកក្នុងការធ្វើការ ឬចូលរួមនៅក្នុងសកម្មភាពកម្មវិធីពីវ៉ែលហ្វែរទៅធ្វើការ នោះខោនធីអាចបោះបង់ការកំណត់ពេល 48 ខែ ហើយអ្នកអាចទទួលជំនួយច្រើនជាង 48 ខែ។

សំណើសម្រាប់ការលើកលែង ឬការពន្យា

បើអ្នកគិតថា អ្នកជួបតាមវិធានសម្រាប់ការលើកលែង ឬការពន្យា សូមទាក់ទងបុគ្គលិកធ្វើការរបស់អ្នក។ អ្នកក៏អាចទាក់ទងបុគ្គលិករបស់អ្នកឱ្យស្វែងរកចំនួនខែនៃការផ្តល់ជំនួយដែលបានប្រើ។

ការជ្រើសរើសចាកចេញពីជំនួយសាច់ប្រាក់

បើគ្រួសាររបស់អ្នកកំពុងទទួលបានចំនួនជំនួយសាច់ប្រាក់ប្រចាំខែតិចតួច អ្នកអាចជ្រើសរើសបញ្ចប់ជំនួយ ដូច្នេះ ខែនៃការផ្តល់ជំនួយនោះនឹងមិន រាប់បញ្ចូលការកំណត់ពេល 48 ខែរបស់ CalWORKs របស់អ្នកទេ។ នេះ **នឹង** សន្សំខែមួយចំនួនឱ្យអ្នកសម្រាប់ទទួលជំនួយសាច់ប្រាក់នៅថ្ងៃខាងមុខ។ អ្នកត្រូវទាក់ទងទៅបុគ្គលិកធ្វើការរបស់អ្នក ដើម្បីស្វែងយល់ថាតើការចាកចេញពីជំនួយនឹងមានប្រយោជន៍ដល់អ្នក ឬអត់។

កម្មវិធីបង្វែរ

មានវិធានស្តីពីការកំណត់ពេលពិសេសសម្រាប់កម្មវិធីបង្វែរ។ កម្មវិធីបង្វែរ គឺជាការបង់ប្រាក់សរុបដែលអ្នកអាចទទួលបានជំនួសពីការទទួលជំនួយសាច់ប្រាក់ប្រចាំខែ។ ខែដែលអ្នកទទួលបានចំនួនទឹកប្រាក់ពីកម្មវិធីបង្វែរ រាប់ជាមួយខែសម្រាប់ការកំណត់ពេល 48 ខែរបស់ CalWORKs លុះត្រាតែអ្នកជាក់ស្តើម្តងទៀត ហើយទទួលបានជំនួយសាច់ប្រាក់នៅអំឡុងពេលនៃរយៈពេលកម្មវិធីបង្វែរ។ នៅក្នុងករណីនោះ អ្នកអាចជ្រើសរើសយកខែទាំងអស់នៅក្នុងរយៈពេលនៃកម្មវិធីបង្វែរ ដែលរាប់បញ្ចូលទៅក្នុងការកំណត់ពេល 48 ខែ ឬបង់ការបង់ប្រាក់នៃកម្មវិធីបង្វែរម្តងទៀត ដោយបន្ថយការផ្តល់សាច់ប្រាក់ប្រចាំខែរបស់អ្នក។

វិធានសម្រាប់រដ្ឋផ្សេងទៀត

រដ្ឋផ្សេងទៀតមានវិធានស្តីពីការកំណត់ពេលខុសៗគ្នា។ បើអ្នកទទួលបាន ជំនួយ TANF នៅក្នុងរដ្ឋផ្សេងទៀត - ឬបើអ្នកមានគម្រោងផ្លាស់ទៅរដ្ឋផ្សេងទៀត - អ្នកត្រូវតែទាក់ទងរដ្ឋនោះ ដើម្បីស្វែងយល់ពីការតម្រូវស្តីពីការកំណត់ពេលរបស់រដ្ឋនោះ។